សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីការពុលអាហារ ដែលនៅក្នុងរូបភាពទី ១ យើងឃើញស្ត្រីម្នាក់ និងបុរសម្នាក់ ពួកគាត់ទាំងពីរគឺជាអ្នកធ្វើការជាមួយគ្នា ឬក៏ពួកគាត់ទាំងពីរគឺជាមិត្តភក្តិនឹងគ្នា ដែលយើងឃើញបុរសម្នាក់នោះពាក់អាវពណ៌លឿង ដៃខ្លី ជាមួយនឹងខោសជើងវែង និងស្ត្រីម្នាក់នោះ យើងឃើញពាក់អាវពណ៌ក្រហម ដៃខ្លី ជាមួយនឹងខោពណ៌ខ្មៅជើងវែង និងប្លួងសក់ឡើងទៅលើ។ ពួកគាត់ទាំងពីរបានបបួលគ្នាចេញមកខាងក្រៅ ដើម្បីញ៉ាំគ្រឿងសមុទ្រជាមួយគ្នា។ ដោយសារតែថ្ងៃនេះគឺជាថ្ងៃឈប់សម្រាក អញ្ចឹងមានន័យថាថ្ងៃនេះពួកគាត់អត់ធ្វើការទេ ដូច្នេះពួកគាត់ទាំងពីរក៏បានបបួលគ្នាចេញទៅខាងក្រៅដើម្បីញ៉ាំគ្រឿងសមុទ្រ។ យើងឃើញពួកគាត់អង្គុយនៅហាងមួយ ដែល[នៅ]ហាងនោះ គឺលក់គ្រឿងសមុទ្រជាច្រើន លក់គ្រឿងសមុទ្រជាច្រើន ដែលយើងឃើញពួកគាត់ទាំងពីរបានហៅម្ហូប បានហៅម្ហូបគ្រឿងសមុទ្រ នៅលើ បានហៅម្ហូបគ្រឿងសមុទ្រ ដែលមានអយស្ទ័រ ដែលមានអយស្ទ័រមួយចាន ដែលមានអយស្ទ័រមួយចាន និងម្ហូបដទៃទៀតដែលគាត់ដាក់នៅលើតុ និងយើងឃើញមានដបទឹកពីរ យើងឃើញមានដបទឹកពីរដាក់នៅក្បែរពួកគាត់ ដាក់នៅក្បែរពួកគាត់ អញ្ចឹងពួកគាត់ជជែកគ្នាបណ្តើរញ៉ាំបណ្តើរ ដោយយើងឃើញនៅក្នុងហាងនោះ យើងឃើញមានភ្ញៀវជាច្រើនទៀតដែលកំពុងតែអង្គុយ កំពុងអង្គុយញ៉ាំគ្រឿងសមុទ្រនោះ និងអង្គុយញ៉ាំផង ជជែក អង្គុយញ៉ាំបណ្តើរជជែកគ្នាលេងបណ្តើរ។ អញ្ចឹងយើងឃើញមានភ្ញៀវជាច្រើននៅក្នុងហាងនោះ ការលក់គ្រឿងសមុទ្រមិនមែនលក់នៅក្នុងហាងទំនើបៗ ឬក៏ថ្លៃៗទេ នៅកម្ពុជាការលក់គ្រឿងសមុទ្រ ពេលខ្លះយើងឃើញមានច្រើន មានលក់ច្រើននៅតាមចិញ្ចើមផ្លូវ [...] នៅតាមចិញ្ចើមផ្លូវ ដែលអ្នកខ្លះ គាត់មានផ្ទះផ្ទាល់ខ្លួន អញ្ចឹងគាត់បើកហាងលក់គ្រឿង គាត់បើកហាងលក់គ្រឿងសមុទ្រតូច លក់គ្រឿងសមុទ្រតូចមួយ និងដាក់តម្រៀបតុនិងកៅអីនៅតាមចិញ្ចើមផ្លូវ អ្នកខ្លះគាត់ជួលផ្ទះ ឬក៏គាត់ជួលហាង បន្ទាប់មកគាត់ដាក់តម្រៀបតុ ឬក៏កៅអី នៅតាម នៅតាមផ្លូវ។ អញ្ចឹងការលក់គ្រឿងសមុទ្រនៅកម្ពុជាមានហាងជាច្រើនលក់ និងហាងទាំងអស់នោះភាគច្រើន គឺលក់នៅតាមចិញ្ចើមផ្លូវ និងមានមនុស្សជាច្រើនចូលចិត្តទៅញ៉ាំ និងមានមនុស្សជាច្រើនចូលចិត្តទៅញ៉ាំ ដោយសារតែនៅ ដោយសារតែការលក់នៅតាមចិញ្ចើមផ្លូវ គឺមានតម្លៃថោកជាងការលក់នៅតាមហាងធំៗ ឬក៏ហាងទំនើបៗ និង និងការលក់នៅតាម និងម្ហូបអាហារដែលលក់នៅតាមចិញ្ចើមផ្លូវខ្លះមានរសជាតិឆ្ងាញ់ មានរសជាតិឆ្ងាញ់ អញ្ចឹងយើងឃើញរូបភាពទី ១ នេះ ពួកគាត់ទាំងពីរជជែកគ្នាបណ្តើរញ៉ាំបណ្តើរ។

ដែលនៅក្នុងរូបភាពទី ២ រូបភាពទី ២ យើងឃើញនៅលើតុគាត់ នៅក្នុងចាន យើងឃើញមានអយស្ទ័រជាច្រើន យើងមានអយស្ទ័រជាច្រើននៅក្នុងចាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងពួកគាត់បានហៅអយស្ទ័រញ៉ាំ ដោយអយស្ទ័រនៅ អយស្ទ័រនៅកម្ពុជាយើងហៅ នៅ អយស្ទ័រធំៗ យើងហៅថា យើងហៅវាអយស្ទ័រ ប៉ុន្តែខ្លះយើងហៅវាថាលៀស អញ្ចឹងអយស្ទ័រមានពីរប្រភេទ មួយយើងហៅថាលៀស មួយទៀតយើងហៅថាអយស្ទ័រ លៀសគឺវានៅក្នុងទឹកទន្លេ យើងអាចរកវាបាននៅក្នុងទឹកទន្លេ និងលៀសគឺសំបករបស់ និងលៀស រូបរាងរបស់វាគឺតូច និងរូបរាងរបស់វាតូច និងសំបករបស់វានៅខាងលើមិនសូវគ្រើមដូចជាថ្មខ្លាំងទេ វា វា វាមានគន្លាក់ៗ ប៉ុន្តែវាអត់សូវគ្រើមដូចជាអយស្ទ័រទេ អយស្ទ័រសំបករបស់វាគ្រើម ដូច នៅពេលដែលយើងប៉ះវា នៅពេលដែលយើងប៉ះសំបកវា មានអារម្មណ៍ថាដូចជាដុំថ្ម ដូចជាដុំថ្ម។ អញ្ចឹងលៀសគឺយើង រូបរាងរបស់វាតូច និងយើងអាចយកវា និងយើងអាចរកវាបាននៅតាមទន្លេ នៅក្នុងទន្លេ និងលៀសនៅពេលដែលយើងរកវាបាន យើងយកលៀសនោះមកប្រឡាក់ជាមួយអំបិល និងម្ទេស បន្ទាប់មកយើងដាក់ហាលថ្ងៃ ដើម្បីឲ្យពន្លឺថ្ងៃ ដើម្បីឲ្យពន្លឺថ្ងៃធ្វើឲ្យលៀសនោះឆ្អិន។ នៅពេលដែលលៀសនោះឆ្អិន យើងអាចញ៉ាំបាន និងពេលខ្លះប្រសិនបើយើង ប្រសិនបើពេលខ្លះ អត់សូវមានពន្លឺថ្ងៃ យើងអាចស្រុសលៀសនោះបន្តិចសិន យើងអាចស្រុសលៀសនោះឲ្យវាឆ្អិនបន្តិច។ បន្ទាប់មកយើងអាចដាក់វានៅក្រោមពន្លឺថ្ងៃ ដើម្បីឲ្យវាឆ្អិន អញ្ចឹងលៀសខុសពីអយស្ទ័រ ដោយសារតែអយស្ទ័រយើងមិនចាំបាច់ យើងមិនបាច់ យើងមិនចាំបាច់ចម្អិនវា ឬក៏ដាក់វានៅហាលថ្ងៃទេ អយស្ទ័រគឺវាធំជាងលៀស និងសំបករបស់វារាងគ្រើមៗដូចជាថ្ម និងអយស្ទ័រភាគច្រើនយើងញ៉ាំឆៅ មានន័យថាយើងយកអយស្ទ័រនោះទៅដាក់ក្លាសេជាមួយនឹងទឹកកក ដើម្បីនៅពេលដែលយើងញ៉ាំកុំឲ្យមានក្លិនឆ្អាប អញ្ចឹងយើងដាក់ក្លាសេជាមួយនឹងទឹកកក អយស្ទ័រខ្លះយើងអាចយកវាទៅអាំង អញ្ចឹងយើងអាចញ៉ាំអយស្ទ័រអាំង ឬក៏ញ៉ាំអយស្ទ័រស្រស់ ដែលគ្រាន់តែដាក់ក្លាសេជាមួយនឹងទឹកកក គ្រឿងផ្សំដែលយើងដាក់ជាមួយនឹងអយស្ទ័រនៅពេលដែលញ៉ាំភាគច្រើននៅកម្ពុជា យើងឃើញពួកគាត់ប្រើស្លឹកកន្ធំថេត [ក្រូម្តទេស] ស្លឹកកន្ធំថេត និងគាត់ប្រើខ្ទឹមលីង គាត់ប្រើខ្ទឹមលីង និងទឹកជ្រលក់របស់ ទឹកជ្រលក់របស់គ្រឿងសមុទ្រ។ អញ្ចឹងគាត់អាចដាក់ខ្ទឹមលីងនៅលើ នៅក្នុងអយស្ទ័រនោះ បន្ទាប់មកគាត់យកស្លឹកកន្ធំថេតបេះដាក់នៅលើអយស្ទ័រនោះ និងគាត់ដាក់ទឹកជ្រលក់ខ្លះនៅលើ ដើម្បី [...] ដើម្បី ដើម្បីឲ្យអយស្ទ័រនោះចូលជាមួយនឹងបន្លែ។ អញ្ចឹងនៅពេលដែលយើងញ៉ាំមានរសជាតិឆ្ងាញ់។ អញ្ចឹងយើងថែមទឹកជ្រលក់បន្តិច និងអយស្ទ័រវាអត់រស់នៅក្នុងទឹកទន្លេទេ អយស្ទ័រគឺរស់នៅក្នុងទឹកសមុទ្រ។ អញ្ចឹងអយស្ទ័រ និងលៀសខុសគ្នា លៀសគឺនៅក្នុងទន្លេ និងលៀសមានរូបរាងតូច មានរូបរាងតូច និងយើងដាក់ហាលវានៅក្រោមពន្លឺថ្ងៃ អយស្ទ័រវាធំជាងលៀស និងសំបករបស់វា សំបក[របស់វា] សំបករបស់វាគ្រើមៗ ប៉ះទៅដូចជាផ្កាថ្ម ឬក៏ថ្ម អញ្ចឹងយើងញ៉ាំវាដោយ យើងញ៉ាំ យើងញ៉ាំវាដោយ ដោយដាក់ក្នុង យើងញ៉ាំវាដោយមិនចាំបាច់ចម្អិន ដោយគ្រាន់តែដាក់វាក្លាសេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងញ៉ាំជាមួយនឹងស្លឹកកន្ទំថេត បន្ទាប់មកដាក់ជាមួយនឹងខ្ទឹមលីង និងទឹកជ្រលក់របស់វាជាការស្រេច និងពេលខ្លះយើងអាច យកអយស្ទ័រនោះទៅអាំងបាន អញ្ចឹងអ្នកខ្លះគាត់ចូលចិត្តញ៉ាំអយស្ទ័រអាំង អ្នកខ្លះគឺគាត់ចូលចិត្តញ៉ាំអយស្ទ័រស្រស់ មានន័យថាគ្រាន់តែដាក់នៅក្នុងធុងក្លាសេ បន្ទាប់មកយើងអាចញ៉ាំវាបាន។

បន្ទាប់មកទៀតរូបភាពទី ៣ បុរសម្នាក់នោះបានកាន់ បានយកអយស្ទ័រមួយចេញ ចេញពីក្នុងចានដើម្បីយកមកញ៉ាំ ប៉ុន្តែមុនពេលញ៉ាំគាត់បានលើកអយស្ទ័រនោះយកមកហិត ដោយសារតែគាត់មានធុំក្លិនចំឡែក ដោយសារតែគាត់មានធុំក្លិនចំឡែក ឬក៏ធុំក្លិនស្អុយចេញពីអយស្ទ័រនោះ អញ្ចឹងគាត់យកវាមកហិតសិន ប៉ុន្តែនៅពេលដែលគាត់ហិតហើយ គាត់មិនបានបោះចោលអយស្ទ័រនោះទេ ដោយទោះបីជាមានក្លិនចំឡែក ឬក៏ក្លិនស្អុយ គាត់នៅតែបន្តញ៉ាំអយស្ទ័រនោះរហូតដល់អស់ ដោយគាត់មិនបានចាប់អារម្មណ៍ថាប្រសិនបើញ៉ាំគ្រឿងសមុទ្រដែល ដែលមានក្លិនស្អុយដូច្នេះអាចធ្វើឲ្យពុល អាចធ្វើឲ្យពុល ឬក៏អាចធ្វើឲ្យឈឺបាន អាចធ្វើឲ្យឈឺបាន ដោយសារតែអយស្ទ័រទាំងនោះគឺ នៅពេលដែលមានក្លិនស្អុយ គឺយើងអត់ញ៉ាំវាទេ អយស្ទ័រដែលមានក្លិនស្អុយប្រហែលជាដោយសារតែ ដោយសារតែយើងទុកយូរថ្ងៃ យើងទុកយូរថ្ងៃ មានន័យថាប្រហែលជាអត់មានភ្ញៀវ អត់មានភ្ញៀវហៅអយស្ទ័រនោះញ៉ាំ ដូច្នេះអ្នកលក់ទុកយូរថ្ងៃ ដូច្នេះធ្វើឲ្យអយស្ទ័រនោះមានក្លិនស្អុយ និងអយស្ទ័រនោះ នៅពេលដែលយើងញ៉ាំអាចប៉ះពាល់ដល់សុខភាព និងអាចធ្វើឲ្យយើងឈឺបាន។ អញ្ចឹងការញ៉ាំគ្រឿងសមុទ្រ គឺយើងប្រយ័ត្នណាស់ ពីព្រោះគ្រឿងសមុទ្រគឺងាយស្រួលក្នុងការធ្វើឲ្យយើងពុលអាហារ។ ដោយសារតែ ដោយសារតែ ដោយសារតែម្ហូបគ្រឿងសមុទ្រខ្លះមាន មានជាតិពុល ដូចជាសត្វក្តាម ដូចជាក្តាមសមុទ្រ នៅពេលដែលយើងញ៉ាំ យើងត្រូវសម្អាតវាឲ្យស្អាត និងបកសន្ទះ ឬក៏បកកន្លែងដែលវា ដែលយើងគិតថាវាមានជាតិពុល ពីព្រោះក្តាមវាមាន នៅពេលដែលយើងបកសំបកវា យើងមានព្រុយរបស់វានៅខាងលើ នៅពេលដែលយើងបកយក យើង យើងបកយក បកយកស្នូករបស់វាចេញ យើងចាប់ផ្តើមយកព្រុយដែលនៅខាងលើក្តាមនោះ យើងបេះវាចេញ ដើម្បីការពារកុំឲ្យពុល។ ពីព្រោះប្រសិនបើយើងញ៉ាំទាំងព្រុយរបស់វានៅខាងលើនោះ អាចធ្វើឲ្យយើងពុល និងអាចប៉ះពាល់ដល់អាយុជីវិតបាន និង និង និងមួយ និងគ្រឿងសមុទ្រមួយចំនួនទៀតក៏មានជាតិពុលផងដែរ អញ្ចឹងការញ៉ាំគ្រឿងសមុទ្រយើងត្រូវ ការញ៉ាំគ្រឿងសមុទ្រគឺយើងត្រូវមានការប្រុងប្រយ័ត្ន និងឲ្យប្រាកដថាម្ហូបគ្រឿងសមុទ្រនោះគឺស្រស់ គឺស្រស់ ប្រសិនបើម្ហូបគ្រឿងសមុទ្រនោះសល់យូរថ្ងៃក៏អាចធ្វើឲ្យប៉ះពាល់ដល់សុខភាពផងដែរ។ អញ្ចឹងជាក់ស្តែងដូចជាអយស្ទ័រនេះគឺសល់យូរថ្ងៃ ដូច្នេះធ្វើឲ្យគាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះធ្វើឲ្យអយស្ទ័រនោះមានក្លិនស្អុយ និង ឬក៏មានក្លិនចំឡែក
ប៉ុន្តែបុរសម្នាក់នោះគាត់អត់បានខ្វល់ថា គាត់អត់បានខ្វល់ថាអយស្ទ័រនោះនឹងធ្វើឲ្យគាត់ឈឺ
ឬក៏នឹងធ្វើឲ្យគាត់អត់ស្រួលខ្លួនទេ អញ្ចឹងគាត់នៅតែបន្តញ៉ាំអយស្ទ័រនោះរហូតដល់អស់។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ ក្រោយពេលពួកគាត់ញ៉ាំអស់ហើយ
និងពួកគាត់ជជែកគ្នាលេងយ៉ាងសប្បាយរីករាយចប់ហើយ ពួកគាត់ទាំងពីរក៏បាន ក៏បានគិតលុយ
និងដើរចេញមកខាងក្រៅ ដើម្បីត្រលប់ទៅផ្ទះវិញ។ អញ្ចឹងយើងឃើញពួកគាត់ទាំងពីរបានលើកដៃ
បានលើកដៃដើម្បីលាគ្នាត្រលប់ទៅផ្ទះវិញ។ អញ្ចឹងផ្ទះរបស់ស្ត្រីម្នាក់ ស្ត្រីម្នាក់នោះ
នៅផ្លូវខុសពីផ្ទះរបស់បុរសម្នាក់នោះ អញ្ចឹងពួកគាត់ទាំងពីរគឺដើរផ្លូវខុសគ្នា ឬក៏ពួកគាត់ទាំងពីរជិះ
ជិះម៉ូតូ ឬក៏ជិះទុកទុកត្រលប់ទៅផ្ទះវិញខុសគ្នា។
អញ្ចឹងពួកគាត់ទាំងពីរក៏បានលាគ្នាដើម្បីត្រលប់ទៅផ្ទះវិញ។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ បុរសម្នាក់នោះក៏បានមកដល់ផ្ទះ
បន្ទាប់មកគាត់ក៏បានចូលទៅក្នុងផ្ទះ និងអង្គុយនៅលើកៅអី ឬក៏សាឡុង ឬក៏កៅអីសាឡុង ដែល
បន្ទាប់ ដែលយើងឃើញគាត់អង្គុយសម្រាកបន្តិច បន្ទាប់មកគាត់ក៏យកទូរស័ព្ទយកមកចុច
ប្រហែលជាគាត់កំពុងតែ ប្រហែលជាគាត់លេង លេងឆាត ឬក៏គាត់កំពុងតែ គាត់កំពុងតែផ្ញើសារ
ឬក៏ផ្ញើអ៊ីម៉ែលទៅពួកម៉ាករបស់គាត់ អញ្ចឹងយើងឃើញគាត់កាន់ទូរស័ព្ទនៅក្នុងដៃរបស់គាត់
ដែលយើងឃើញនៅលើជញ្ជាំងក្នុងផ្ទះរបស់គាត់មានរូបថតព្យួរនៅទីនោះ និងមាននាឡិកាផងដែរ
អញ្ចឹងយើងឃើញមាននាឡិកាមួយព្យួរនៅជាប់ជញ្ជាំងក្បែរនឹង ក្បែរនឹងរូបថតរបស់គាត់
អញ្ចឹងគាត់កំពុងតែចុចទូរស័ព្ទលេងជាមួយ ចុចទូរស័ព្ទលេង ដោយគាត់លេងឆាត ឬក៏គាត់ផ្ញើអ៊ីម៉ែល
ឬក៏គាត់ផ្ញើសារទៅកាន់ពួកម៉ាករបស់គាត់ ឬក៏គាត់កំពុងតែឆែកហ្វេសប៊ុក
បន្ទាប់ពីមួយម៉ោងក្រោយមក បន្ទាប់ពីមួយម៉ោងក្រោយមក គាត់ក៏មានអារម្មណ៍ថាឈឺពោះ
គាត់ក៏មានអារម្មណ៍ថាឈឺពោះ បន្ទាប់មកគាត់ក៏ទម្លាក់ដៃដែលកាន់ទូរស័ព្ទនោះចុះមកខាងក្រោម
ដោយសារតែគាត់មានអារម្មណ៍ថាឈឺពោះខ្លាំងពេក និងមានអារម្មណ៍ថាកូរនៅក្នុងពោះរបស់គាត់
អញ្ចឹងក្នុងពោះរបស់គាត់មានអារម្មណ៍ថាកូរ និងឈឺពោះខ្លាំង។

បន្ទាប់មកទៀតរូបភាពទី ៦ រូបភាពទី ៦ ដោយសារតែគាត់ឈឺពោះពេក ប្រហែលជាគាត់រាក
ប្រហែលជាគាត់រាក ដូច្នេះគាត់ក៏បានរត់យ៉ាងលឿនចូលទៅក្នុងបន្ទប់ទឹក ដើម្បីចូលបង្គន់បត់ជើង
ដើម្បីចូលបង្គន់បត់ជើង ដោយសារតែពោះរបស់គាត់
ក្រោយពេលដែលគាត់ត្រលប់មកពីញ៉ាំគ្រឿងសមុទ្រវិញដោយគាត់ញ៉ាំ
ដោយគាត់បានញ៉ាំអយស្ទ័រដែលមានក្លិនស្អុយ ឬក៏អយស្ទ័រដែលមានក្លិនចំឡែកនោះ ធ្វើឲ្យពោះគាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ធ្វើឲ្យពោះគាត់ឈឺ និងកូរនៅខាងក្នុងពោះរបស់គាត់ និងធ្វើឲ្យគាត់មានអារម្មណ៍ថា ដូចជាចង់បត់ជើងធំ ដូចជាចង់បត់ជើងធំ បន្ទាប់មកគាត់ក៏រត់យ៉ាងលឿនតម្រង់ចូលទៅ តម្រង់ទៅបន្ទប់ទឹកដើម្បីចូលបង្គន់ ដែលយើងឃើញដៃខាង ដៃខាងឆ្វេងរបស់គាត់ គឺកាន់ពោះដោយសារតែគាត់ឈឺខ្លាំងពេក ដៃខាងឆ្វេងគឺគាត់ឈោងទៅបើកទ្វារបង្គន់។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ [នៅគាត់] នៅពេលដែលគាត់ដើរចូលទៅក្នុង[បង្គន់] នៅពេលដែលគាត់រត់ចូលទៅក្នុងបង្គន់ គាត់ក៏បានស្រាតខោរបស់គាត់ដើម្បី ដើម្បីបត់ជើងធំ អញ្ចឹងយើងឃើញ យើងឃើញគាត់កំពុងតែបត់ជើងធំ និងដៃខាង និងដៃខាងស្តាំ និងដៃខាង ដៃខាងស្តាំរបស់គាត់គឺកាន់ទឹក ទឹកសម្រាប់បាញ់សម្អាតគូទ នៅពេលដែលគាត់បត់ជើងធំរួចរាល់ហើយ អញ្ចឹងដៃខាងស្តាំកាន់ទឹកសម្រាប់បាញ់គូទ នៅពេលដែលបាញ់ទឹកសម្រាប់បាញ់គូទ ឬក៏បាញ់ទឹកសម្រាប់ កាន់ទឹកសម្រាប់បាញ់គូទ ឬក៏កាន់ទឹក កាន់ទឹកសម្រាប់លាងសម្អាតគូទរបស់គាត់ នៅពេលដែលគាត់បត់ជើងធំហើយ អញ្ចឹងយើងឃើញគាត់អង្គុយបត់ជើងធំ ដោយដៃរបស់គាត់ខាង ដៃរបស់គាត់ខាងឆ្វេងដាក់ ដាក់ ដាក់នៅលើពោះរបស់គាត់ដោយសារតែគាត់ឈឺពោះខ្លាំងពេក អញ្ចឹងប្រហែលជាគាត់រាក ឬក៏គាត់ពុលអាហារ គាត់រាក គាត់រាកដោយសារតែគាត់ពុល ពុលគ្រឿងសមុទ្រនៅពេលដែលគាត់ញ៉ាំអយស្ទ័រនោះ។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ ក្រោយពេលដែលគាត់បត់ជើងធំហើយ គាត់មានអារម្មណ៍ថាធូរបន្តិច ប៉ុន្តែនៅក្នុងពោះរបស់គាត់នៅតែកូរ និងមានអារម្មណ៍ថាឈឺខ្លាំង អញ្ចឹងមានអារម្មណ៍ថាឈឺខ្លាំង អញ្ចឹងគាត់ក៏បានដើរ ដើរចេញពីក្នុងបន្ទប់ទឹកដោយអស់ ដោយយើងមើលរូបរាងរបស់គាត់គឺមានអារម្មណ៍ថាអស់កម្លាំង អស់កម្លាំងដោយសារតែគាត់ ដោយសារតែគាត់រាក ដោយសារតែគាត់រាក អញ្ចឹងយើងឃើញគាត់អស់កម្លាំង ក្រោយពេលដែលដើរចេញពីបន្ទប់ទឹក ដោយដៃខាងស្តាំរបស់គាត់កាន់ពោះជាប់ ឬក៏ឱបពោះរបស់គាត់[ជាប់] យ៉ាងជាប់ ដោយសារតែគាត់ឈឺពោះខ្លាំងពេក។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ ក្រោយពេលដែលគាត់រាក ក្រោយពេលដែលគាត់រាក និងក្រោយពេលដែលគាត់រាក និងគាត់ត្រលប់ និងគាត់ចេញពីបន្ទប់ទឹកវិញ គាត់ក៏អង្គុយនៅលើកៅអី បន្ទាប់មកពោះរបស់គាត់នៅតែមានអារម្មណ៍ថាកូរ អញ្ចឹងមានអារម្មណ៍ថាកូរ និងមានអារម្មណ៍ថាចង់ក្អួត បន្ទាប់មកគាត់ក៏យកធុង គាត់ក៏យកធុង និងក្អួតចេញមកខាងក្រៅ ដើម្បីឲ្យស្រួលខ្លួន ដើម្បីឲ្យបានស្រួលខ្លួន អញ្ចឹងការពុលអាហារ គឺពិបាក ការពុលអាហារ គឺរោគសញ្ញានៃការពុលអាហារជាទូទៅ គឺយើងក្អួត និងរាក គឺយើងក្អួត និងរាក។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងពេលខ្លះនៅពេលដែលយើងពុលអាហារ ឬក៏ញ៉ាំអាហារដែល ញ៉ាំអាហារខុសធ្វើឲ្យយើងក្អួត និងរាក និងឈឺពោះយ៉ាងខ្លាំង។ អញ្ចឹងជាក់ស្ដែងដូចជាបុរសម្នាក់នេះ គាត់ញ៉ាំអយស្ទ័រដែល ដែលអត់ស្រស់ អយស្ទ័រដែលសល់យូរថ្ងៃ ដូច្នេះធ្វើឲ្យគាត់ក្អួតផងរាកផង ធ្វើឲ្យគាត់ក្អួតផងរាកផង។ អញ្ចឹងគាត់កំពុងតែពុលអាហារ គាត់កំពុងតែពុលអាហារ។ អញ្ចឹងគាត់កាន់ធុងរបស់គាត់នៅក្នុងដៃទាំងពីរ អញ្ចឹងគាត់ក្អួត គាត់ក្អួតដាក់ធុងនោះ គាត់ក្អួតដាក់ធុងនោះ។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ ក្រោយពេលដែលគាត់ក្អួត ក្អួតអស់ហើយ គាត់មានអារម្មណ៍ថារាងធូរបន្តិច រាងធូរបន្តិច ប៉ុន្តែពោះរបស់គាត់នៅតែកូរ និងឈឺយ៉ាងខ្លាំង និងមានអារម្មណ៍ថាមិនសូវស្រួលខ្លួន។ បន្ទាប់មកទៀត ក្រោយពេលដែលគាត់ក្អួត គាត់ក៏បានយកកែវមកដាក់ទឹក បន្ទាប់មកគាត់ក៏បានខ្ពុរមាត់របស់គាត់ ដើម្បីអស់នូវជាតិកម្អួតនោះនៅក្នុងមាត់របស់គាត់ ពីព្រោះប្រសិនបើអត់ខ្ពុរទេមានអារម្មណ៍ថាឆ្អាបនៅក្នុងមាត់ ឬក៏មានអារម្មណ៍ថាអត់ មានអារម្មណ៍ថាចង់ មានអារម្មណ៍ថានៅក្នុងមាត់របស់យើងដូចជាមានក្លិនអ្វីដែល ពីព្រោះ ដូចជាមានក្លិនអ្វីដែលស្អុយ ដោយសារតែនៅពេលដែលក្អួតអាហារដែលចេញពីក្នុង[មាត់] ក្នុងពោះ គឺចេញមកតាមមាត់ អញ្ចឹងអាហារខ្លះដែលមានក្លិនស្អុយ គឺនៅជាប់នៅក្នុងមាត់របស់យើង អញ្ចឹងយើងត្រូវខ្ពុរវាដើម្បីឲ្យមានអារម្មណ៍ថាស្រឡះក្នុងខ្លួនបន្តិច អញ្ចឹងយើងឃើញគាត់កាន់ទឹកមួយកែវ និងខ្ពុរមាត់ នៅក្នុងបន្ទប់ទឹក ដែលបន្ទប់ទឹករបស់គាត់ យើងឃើញមានកញ្ចក់ប្រើសម្រាប់ឆ្លុះមុខដាក់នៅជាប់នឹងជញ្ជាំង អញ្ចឹងគាត់កំពុងតែខ្ពុរមាត់នៅក្បែរកញ្ចក់នោះ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ ក្រោយពេលដែលគាត់ក្អួត និងខ្ពុរមាត់ហើយ គាត់មានអារម្មណ៍ថាអស់កម្លាំងយ៉ាងខ្លាំង និងឈឺពោះ និងនៅតែឈឺពោះ និងនៅតែឈឺនៅក្នុងពោះ អញ្ចឹងបន្ទាប់មកគាត់ក៏ដើរត្រលប់មកសាឡុង ឬក៏គាត់ ដើរត្រលប់មកសាឡុងវែង ដើម្បី ដើម្បីគេង ឬក៏សម្រាកបន្តិច ដើម្បីគេង ឬក៏សម្រាកបន្តិច យើងឃើញគាត់ ជើងម្ខាងគាត់សណ្ដូក គាត់ដេក[សណ្ដូក] គាត់គេងសណ្ដូកជើងម្ខាង និងជើងម្ខាងទៀតគាត់ដាក់ គាត់ដាក់បញ្ឈរផ្អែកទៅនឹងសាឡុងនោះ ផ្អែកទៅនឹងសាឡុងនោះ អញ្ចឹងគាត់ និងដៃរបស់គាត់ខាងស្ដាំនៅតែកាន់ ឬក៏ឱបពោះរបស់គាត់ ដោយសារតែគាត់ឈឺនៅក្នុងពោះខ្លាំងពេក និងមានអារម្មណ៍ថាមិនស្រួលខ្លួន និងមានអារម្មណ៍ថាមិនស្រួលខ្លួន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១២ ដោយសារតែគាត់រាកផងក្អួតផង
បន្ទាប់មកទៀតគាត់ក៏ដើរទៅយកម្សៅជាតិរ៉ែ ដែលអាចជួយឲ្យ
ដែលម្សៅជាតិរ៉ែនោះអាចជួយឲ្យពោះរបស់គាត់ឈប់ឈឺ និងឈប់ក្អួត និងឈប់ក្អួត និងឈប់រាក។
អញ្ចឹងគាត់ក៏បានយកម្សៅរ៉ែនោះមួយកញ្ចប់ បន្ទាប់មកយើងឃើញគាត់ហែក ហែកម្សៅនោះ
ដើម្បីដាក់ចូលទៅក្នុងកែវ ដើម្បី ដើម្បីដាក់ចូលទៅក្នុងកែវញ៉ាំ។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ គាត់ក៏យកកែវដាក់ទឹក
គាត់ក៏យកកែវដាក់ទឹកនៅខាងក្នុងកែវនោះ
បន្ទាប់មកគាត់ក៏បានយកស្លាបព្រាដួសយកម្សៅដែលមានជាតិរ៉ែចេញពីកញ្ចប់ម្សៅនោះ
ដាក់ចូលទៅក្នុងកែវលាយជាមួយនឹងទឹកដើម្បីញ៉ាំ ដើម្បីឲ្យមានអារម្មណ៍ថាស្រួលខ្លួន
ឲ្យមានអារម្មណ៍ ដើម្បីឲ្យមានកម្លាំងវិញ ក្រោយពេលដែលគាត់រាកផងក្អួតផង។
អញ្ចឹងគាត់ត្រូវញ៉ាំទឹកឲ្យបានច្រើន និងញ៉ាំម្សៅដែលមានជាតិរ៉ែនេះដើម្បីឲ្យជាតិពុល
ឬក៏ដើម្បីឲ្យមានអារម្មណ៍ថាស្រួលខ្លួន ដើម្បីឲ្យស្រួលខ្លួន និងដើម្បីឲ្យជាតិពុលទាំងអស់នោះ
ដើម្បីឲ្យជាតិពុលទាំងអស់នោះចេញ ចេញមកខាងក្រៅឲ្យអស់
និងម្សៅជាតិរ៉ែនោះជួយឲ្យយើងកុំឲ្យឈឺពោះ ឬក៏ក្អួត ឈឺពោះ ឬក៏ក្អួត
និងជួយឲ្យយើងមានកម្លាំងផងដែរ ដោយសារតែនៅពេលដែលយើងរាក
រាកផងក្អួតផងធ្វើឲ្យយើងមានអារម្មណ៍ថាអស់ជាតិទឹក និងអស់កម្លាំងយ៉ាងខ្លាំង
ដូច្នេះយើងត្រូវញ៉ាំម្សៅជាតិរ៉ែនោះ និងញ៉ាំទឹកឲ្យបានច្រើន។
អញ្ចឹងគាត់បានយកស្លាបព្រាដួសម្សៅជាតិរ៉ែ ដួសម្សៅដែលមានជាតិរ៉ែនោះដាក់ចូលទៅក្នុងកែវទឹក
លាយជាមួយទឹកដើម្បីយកមកញ៉ាំ។

បន្ទាប់មកទៀតរូបភាពទី ១៤ ក្រោយពេលដែលគាត់លាយម្សៅនោះជាមួយនឹងទឹកនោះស្មើគ្នាហើយ
គាត់ក៏បាន គាត់ក៏បានលើកកែវនោះយកមកញ៉ាំ អញ្ចឹងដៃខាងស្ដាំរបស់គាត់កាន់កែវនោះ
និងគាត់ដាក់កែវនោះ ដើម្បីញ៉ាំទឹក និងញ៉ាំម្សៅដែលមានជាតិរ៉ែ ដែលគាត់បានលាយនៅក្នុងទឹកនោះ
ដើម្បីធ្វើឲ្យគាត់មានកម្លាំងឡើងវិញ អញ្ចឹងគាត់កំពុងតែញ៉ាំ
កំពុងតែញ៉ាំម្សៅជាតិរ៉ែដែលលាយជាមួយទឹកនោះ។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ ក្រោយពេលដែលគាត់ញ៉ាំ ញ៉ាំម្សៅជាតិរ៉ែ
ដែលលាយជាមួយនឹងទឹកដាក់ចូលទៅក្នុងកែវនោះញ៉ាំហើយ គាត់ក៏បានដើរត្រលប់មកសាឡុងវិញ
គាត់ដើរត្រលប់មកសាឡុងវែងវិញ បន្ទាប់មកគាត់ក៏បានគេងសម្រាកម្ដងទៀត
ក្រោយពេលដែលញ៉ាំថ្នាំ ជាទូទៅយើង យើងគេងសម្រាកដើម្បីឲ្យជាតិថ្នាំនោះចូលទៅ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ជ្រាបចូលទៅខាងក្នុង ដើម្បីធ្វើឲ្យយើងមានអារម្មណ៍ស្រួលខ្លួនវិញ។
យើងឃើញខ្មើយធ្លាក់ចុះទៅខាងក្រោម អញ្ចឹងយើងឃើញខ្មើយមួយគាត់ដាក់កើយ
ខ្មើយមួយទៀតគឺគាត់ទម្លាក់ចុះទៅខាងក្រោម ឬក៏ធ្លាក់ចុះទៅខាងក្រោម ខាងក្រោមដោយខ្លួនវា។
ដោយសារតែគាត់ឈឺពោះពេក
ដូច្នេះគាត់មិនបានចាប់អារម្មណ៍ថាមានខ្មើយធ្លាក់ចុះទៅខាងក្រោមទេ។ យើងឃើញគាត់
គាត់គេងបន្តិច និងដៃរបស់គាត់នៅតែឱបពោះរបស់គាត់ដោយសារតែមានអារម្មណ៍ថាកូរ
ពោះរបស់គាត់កូរខ្លាំង និងឈឺពោះចង់ក្អួត។

បន្ទាប់មកទៀតរូបភាពទី ១៦ រូបភាពទី ១៦ ក្រោយពេលគាត់សម្រាកមួយសន្ទុះ
និងម្សៅដែលមានជាតិ និង និងម្សៅដែលមានជាតិរ៉ែនោះ ក្រោយពេលដែលគាត់ញ៉ាំ
និងសម្រាកមួយសន្ទុះ គាត់ក៏ក្រោកឡើងមានអារម្មណ៍ថាស្រួលខ្លួនបន្តិច
គាត់ក៏មានអារម្មណ៍ស្រួលខ្លួនបន្តិច។ អញ្ចឹងយើងឃើញគាត់ក្រោកអង្គុយ មាន គាត់ក្រោកអង្គុយ
មើលទៅគាត់មានកម្លាំង គាត់មានកម្លាំងបន្តិច និង[ស្រួល] គាត់មានកម្លាំង គាត់មានកម្លាំងជាងមុន
នៅពេលដែលគាត់ញ៉ាំ នៅពេលដែលគាត់ញ៉ាំថ្នាំហើយ បន្ទាប់មកគាត់គេងមួយសន្ទុះ
ឬក៏សម្រាកមួយសន្ទុះ

បន្ទាប់មកទៀតនៅពេលដែលគាត់មានអារម្មណ៍ថាស្រួលខ្លួនឡើងវិញ រូបភាពទី ១៥
គាត់ក៏បានយកទូរស័ព្ទតេទៅប្រាប់ពួកម៉ាករបស់គាត់
ដើម្បីចង់ដឹងថាតើពួកម៉ាករបស់គាត់មានអាការដូចជាគាត់ដែរឬទេ
ឬក៏ពួកម៉ាករបស់គាត់ពុលគ្រឿងសមុទ្រដូចជាគាត់ដែរឬទេ អញ្ចឹងគាត់ក៏បានប្រាប់រឿងរ៉ាវ
ដែលគាត់បានញ៉ាំអយស្ទ័រដែលមានក្លិនស្អុយ បន្ទាប់មកគាត់ ពេល
នៅពេលដែលគាត់ត្រលប់មកផ្ទះវិញគាត់ឈឺពោះ និងឈឺពោះរាក និងឈឺពោះផង រាកផង ក្អួត
ឈឺពោះផង ក្អួតផង និងរាកផង។ អញ្ចឹងធ្វើឲ្យគាត់មានអារម្មណ៍ថាអស់កម្លាំងយ៉ាងខ្លាំង
និងមិនស្រួលខ្លួន និងមិនស្រួលខ្លួន។
អញ្ចឹងគាត់បានរៀបរាប់នូវអាការពុលអាហាររបស់គាត់ទៅប្រាប់ពួកម៉ាករបស់គាត់ និងគាត់តេទូរស័ព្ទ
ឬក៏គាត់ខលទូរស័ព្ទទៅពួកម៉ាករបស់គាត់ ដើម្បីចង់ដឹងថាតើពួកម៉ាករបស់គាត់មានអាការ
ឬក៏ពួកម៉ាករបស់គាត់មិនស្រួលខ្លួនដូចជាគាត់ដែរឬទេ
ដោយសារតែពួកគាត់ទាំងពីរញ៉ាំគ្រឿងសមុទ្រជាមួយគ្នា និងនៅក្នុងចានតែមួយ ប៉ុន្តែពេលខ្លះ
ចានខ្លះគឺគាត់បានដាក់អយស្ទ័រលាយបញ្ចូលគ្នា អយស្ទ័រខ្លះស្រស់ អយស្ទ័រខ្លះគឺ
គឺស្អុយដែលសល់រយៈពេលយូរ អញ្ចឹងពេលខ្លះអាចពួកម៉ាកគាត់ របស់គាត់យក
អាចពួកម៉ាករបស់គាត់សំណាងល្អ ពួកម៉ាករបស់គាត់ញ៉ាំតែអយស្ទ័រដែលស្រស់ ប៉ុន្តែដោយសារ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប្រហែលជាថ្ងៃនេះគឺជាថ្ងៃដែលមិនល្អសម្រាប់ គឺជាថ្ងៃដែល គឺជាថ្ងៃអត់ល្អរបស់គាត់ ដូច្នេះធ្វើឲ្យគាត់នៅពេល ដូច្នេះធ្វើឲ្យគាត់ពុលគ្រឿងសមុទ្រ ធ្វើឲ្យគាត់ពុលសមុទ្រ និងក្អួតផង រាកផង។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.